**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.[illegible]

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ[illegible] ឆ្នាំ២០១៥

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ**

**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន**

**កម្មវត្ថុ** : ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ។

**យោង** : ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ លើលិខិតលេខ ១២៥៨ សហវ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថាៈ ស្របតាមផែនការសកម្មភាពនៃឯកសារទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០ សម្តេចតេជោនាយករដ្ឋមន្ត្រីបានសម្រេចដូចខាងក្រោមៈ

១. ដាក់ឱ្យក្រសួង-ស្ថាប័នចំនួន ១៥ និងមន្ទីរជំនាញពាក់ព័ន្ធអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំ២០១៦ រួមមានៈ តុលាការកំពូល, សាលាឧទ្ធរណ៍, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងពត៌មាន, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ ស្របតាមការសម្រេចនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តជាខ្សែបណ្តោយខាងលើត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីក្នុងឆ្នាំ២០១៥ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ។

២. ដាក់ឱ្យក្រសួង-ស្ថាប័នចំនួន ១១ និងមន្ទីរជំនាញពាក់ព័ន្ធអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំ២០១៧ រួមមានៈ ក្រសួងព្រះបរមរាជវាំង, ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងរ៉ែ និងថាមពល, ក្រសួងធម្មការ និងសាសនា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ក្រសួងផែនការ និងក្រសួងមុខងារសាធារណៈ ។ ស្របតាមការសម្រេចនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តជាខ្សែបណ្តោយខាងលើត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីក្នុងឆ្នាំ២០១៦ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ។

៣. ដាក់ឲ្យក្រសួង-ស្ថាប័នចំនួន ០៣អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំ២០១៨ រួមមានៈ ទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គភាពចំណុះ , ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ (ទាំងផ្នែករដ្ឋបាលស៊ីវិល និងទាំងផ្នែកសន្តិសុខសាធារណៈ)។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងចាត់វិធានការឲ្យបានសមស្របតាមការគួរ ។

សូមសម្តេច ឯកឧត្តម លោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- ប្រកាសលេខ០៦៨ សហវ.ប្រក ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- យោងចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី លើលិខិតលេខ ១២៥៨ សហវ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.** ដាក់ឱ្យក្រសួង ស្ថាប័នចំនួន១៥ និងមន្ទីរជំនាញពាក់ព័ន្ធអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាចាប់ពីឆ្នាំ២០១៦ ដែលរួមមាន៖ តុលាការកំពូល, សាលាឧទ្ធរណ៍, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងព័ត៌មាន, រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា,និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**ប្រការ២.** ក្រសួង ស្ថាប័នទាំង១៥ និងមន្ទីរជំនាញរាជធានីខេត្តពាក់ព័ន្ធ ត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធី និងអង្គភាពថវិកា ក្នុងឆ្នាំ២០១៥ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ។

**ប្រការ៣.** គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្តពាក់ព័ន្ធមានភារកិច្ចដើម្បីអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា ឱ្យទទួលបានជោគជ័យ និងប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ តាមទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា។

**ប្រការ៤.** ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Scan

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០២៦៩ សហវ

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០១៥

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ** : សំណើចេញប្រកាសដាក់ក្រសួង-ស្ថាប័នចំនួន១៥បន្ថែមទៀត ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកាក្នុងឆ្នាំ២០១៦ និងគោលការណ៍សម្រាប់ឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ ។

**យោង** :-មាត្រា២៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨

-របាយការណ៍ស្តីពីការបណ្តុះបណ្តាលថវិកាកម្មវិធី និងអង្គភាពថវិកា (វគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល និងមន្ត្រីថវិកានៃក្រសួង-ស្ថាប័នចំនួន១៥ ពីថ្ងៃទី១៣ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤) ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូនសម្តេចតេជោនាយករដ្ឋមន្ត្រីមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា÷ ក្នុងឆ្នាំ២០១៥នេះ ក្រសួងចំនួន១០បានចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ដែលរួមមាន: ក្រសួងយុត្តិធម៌ (ព្រមទាំងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នមានកញ្ចប់ថវិកាស្ថិតក្រោមក្រសួងយុត្តិធម៌ ដោយឡែកស្ថាប័នតុលាការកំពូល និងសាលាឧទ្ធរណ៍ ដែលមានកញ្ចប់ថវិកាស្ថិតក្រោមក្រសួងយុត្តិធម៌ដែរនោះ បានស្នើសុំអនុវត្តថវិកាមិនមែនកម្មវិធីបន្តទៀតសម្រាប់ឆ្នាំ២០១៥សិន) , ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ , ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណៈការ និងដឹកជញ្ជូន , ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ស្របតាមផែនការសកម្មភាពនៃ**ឯកសារទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០** គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញយ៉ាងយូរបំផុតត្រឹមឆ្នាំ២០១៨ ដើម្បីឱ្យថវិកាកម្មវិធីទាំងមូលអាចឆ្លងការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិបាននៅឆ្នាំ២០២០ ។ ក្នុងគោលដៅពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបន្តបណ្តុះបណ្តាលគ្រូបង្គោល និងមន្ត្រីថវិកានៃក្រសួង-ស្ថាប័នចំនួន១៥ បន្ថែមទៀតរួមមាន: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

និងយុវនីតិសម្បទា, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងមុខងារសាធារណៈ, ក្រសួងទេសចរណ៍, ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ,ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងធនធានទឹក, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, ទីស្តីការគណៈរដ្ឋមន្ត្រី, អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ ។

ក្នុងទិសដៅខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមស្នើសុំគោលការណ៍ និងអភិក្រមដូចខាងក្រោមៈ

១. **ស្នើដាក់ឱ្យក្រសួង-ស្ថាប័នចំនួន ១៥បន្ថែមទៀត** អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឆ្នាំ ២០១៦ ដែលរួមមានៈ តុលាការកំពូល, សាលាឧទ្ធរណ៍, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងព័ត៌មាន, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្នុងករណីមានការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តជាខ្សែបណ្តោយត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីក្នុងឆ្នាំ២០១៥ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ។ តាមជំហាននេះ ក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា នឹងឡើងដល់ចំនួន ២៥ ហើយទំហំថវិកាកម្មវិធីស្មើនឹងប្រមាណ ៥៧,៤ភាគរយនៃចំណាយចរន្តថវិកាប្រចាំឆ្នាំរបស់ថ្នាក់ជាតិ ។

២. **ស្នើដាក់ឱ្យក្រសួង-ស្ថាប័នចំនួន ១១បន្ថែមទៀត** អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឆ្នាំ ២០១៧ ដែលរួមមានៈ ក្រសួងព្រះបរមរាជវាំង , ក្រុមប្រឹក្សាធម្មនុញ្ញ ,ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងរ៉ែ និងថាមពល, ក្រសួងធម្មការ និងសាសនា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ក្រសួងផែនការ និង ក្រសួងមុខងារសាធារណៈ អនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកាក្នុងឆ្នាំ២០១៧។ ក្នុងករណីមានការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តជាខ្សែបណ្តោយ ត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីក្នុងឆ្នាំ២០១៦ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ។ តាមជំហាននេះ ក្រសួង-ស្ថាប័ន អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា នឹងឡើងដល់ចំនួន៣៦ ហើយទំហំថវិកាកម្មវិធីស្មើនឹងប្រមាណ ៦១,៣ភាគរយនៃចំណាយចរន្តថវិកាប្រចាំឆ្នាំរបស់ថ្នាក់ជាតិ។

៣. **ស្នើដាក់ឱ្យក្រសួង-ស្ថាប័នចំនួន ០៣ដែលនៅសល់** អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឆ្នាំ ២០១៨ ដែលរួមមានៈ ទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គភាពចំណុះ, ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ។ តាមជំហានចុងក្រោយនេះ ក្រសួង-ស្ថាប័នថ្នាក់ជាតិទាំងអស់នឹងអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំ ២០១៨។

៤. ទន្ទឹមនេះដែរ **ស្នើដាក់ឱ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិ** ជាពិសេសថវិការបស់សាលារាជធានី-ខេត្ត អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាជាបន្តបន្ទាប់នៅឆ្នាំ២០១៧ និងឆ្នាំ២០១៨ ។ ក្នុងករណីមានការ

សម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ស្ថាប័នថ្នាក់ក្រោមជាតិ នឹងត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីក្នុងឆ្នាំ២០១៦ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ។

តាមជំហ៊ាននៃការដាក់ឱ្យក្រសួង-ស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ អនុវត្តថវិកាកម្មវិធីពេញលេញជាបន្តបន្ទាប់ត្រឹមឆ្នាំ២០១៨ ដូចបានជម្រាបជូនខាងលើ នោះថវិការដ្ឋទាំងមូលនឹងក្លាយជាថវិកាកម្មវិធីពេញលេញដែលអាចអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិនៅក្នុងរង្វង់ឆ្នាំ២០២០។ ដើម្បីគោលដៅនេះ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី ជំនួសច្បាប់ជាធរមានបច្ចុប្បន្ននេះ ឱ្យបានមុនឆ្នាំ២០២០** សម្រាប់ការចាប់អនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធី និងប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល និងសមិទ្ធកម្ម និងមានលក្ខណៈវិសហមជ្ឈការ និងវិមជ្ឈការចាប់ពីឆ្នាំ២០២០ តទៅ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេចតេជោនាយករដ្ឋមន្ត្រីមេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**<u>ចម្លងជូន</u>**

-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់**
ឧបនាយករដ្ឋមន្ត្រីប្រចាំការ